# ការពង្រឹងគ្រួសារ និងការបង្ការការបំបែកកុមារពីគ្រួសារ

Better Care Network

## សេចក្តីសង្ខេបអំពីវីដេអូ

ក្នុងករណីជាច្រើន វាអាចចៀសវាងការបំបែកកុមារពីគ្រួសារ និងការងាកទៅការប្រើប្រាស់ការថែទាំជំនួសបាន តាមរយៈការផ្តល់សេវាគាំទ្រផ្នែកសង្គម និង សេវាគាំទ្រគ្រួសារនៅតាមសហគមន៍។ បញ្ហាប្រឈម និងបរិបទជាច្រើន គឺធានាយ៉ាងណាឱ្យមានសេវាទាំងនេះ ឱ្យប្រជាជនអាចចូលទៅប្រើប្រាស់សេវាទាំងនេះបាន ហើយធ្វើឱ្យសេវាទាំងនេះ ឆ្លើយតបនឹងតម្រូវការដល់គ្រួសារដែលមានហានិភ័យខ្ពស់នៃការបំបែកកុមារពីគ្រួសារ ជាពិសេសគ្រួសារដែលមានទីតាំងនៅតាមជនបទដាច់ស្រយាល។

ដើម្បីឈានទៅឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ អង្គការទំនុកចិត្តកុមារកម្ពុជា បានអនុវត្តសាកល្បងកម្មវិធីថែរក្សាគ្រួសារបែបសព្វជ្រុងជ្រោយក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា។ ក្នុងវីដេអូនេះ  អ្នកនឹងបានឮលោក ង៉ាត សោភ័ណ្ឌ ចែករំលែកអំពីចំណុចសិក្សារៀនសូត្រសំខាន់ៗមួយចំនួន ទទួលបានពីដំណាក់កាលអនុវត្តគម្រោងសាកល្បងរបស់ខ្លួន។ លោក សោភ័ណ្ឌ លើកឡើងអំពីផលប៉ះពាល់នៃការជ្រើសរើសបុគ្គលិកសង្គមកិច្ចជាអ្នកក្នុងមូលដ្ឋាន មកលើប្រសិទ្ធភាពនៃការកំណត់ហានិភ័យ និងការវិភាគ ហានិភ័យ និងថាតើចំណុចនេះប៉ះពាល់យ៉ាងណាខ្លះចំពោះនិរន្តរភាពនៃលទ្ធផលសម្រាប់គ្រួសារ។ លោកក៏បានពិភាក្សាអំពីសារៈសំខាន់នៃការកសាងទំនាក់ទំនងដ៏រឹងមាំជាមួយគ្រួសារ និងថាតើហេតុអ្វីបានជាអង្គការទំនុកចិត្តកុមារប្រើគោលវិធីផ្អែកលើចំណុចខ្លាំងនៅក្នុងការអនុវត្តការងារសង្គមកិច្ចរបស់ខ្លួន។

## ចំណុចពិភាក្សា៖

### ការពង្រឹងសិទ្ធិអំណាចដល់គ្រួសារ និងផលប៉ះពាល់ប្រកបដោយនិរន្តរភាព

នៅក្នុងវីដេអូនេះ លោក សោភ័ណ្ឌ លើកឡើងអំពីសារៈសំខាន់នៃការបង្កឱ្យមានការចូលរួមពីគ្រួសារក្នុងលក្ខណៈមួយដែលជួយពន្លេចចំណុចខ្លាំង សមត្ថភាព និងបណ្តាញរបស់ពួកគេឱ្យលេចចេញមកយ៉ាងជាក់ច្បាស់ ជំនួសឱ្យការផ្តោតការយកចិត្តទុកដាក់តែទៅលើចំណុចខ្វះខាតរបស់ពួកគេ។ លោកពិភាក្សាឱ្យឃើញថា ការធ្វើបែបនេះជួយបង្កើតឱ្យមានការផ្លាស់ប្តូរការគិតយ៉ាងខ្លាំង ហើយជួយកសាងទំនុកចិត្តរបស់គ្រួសារមកលើសមត្ថភាពរបស់ខ្លួនក្នុងការរួមរស់នៅជាមួយគ្នា និងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កុមារ។

## ក្នុងបរិបទរបស់អ្នក៖

- តើអភិក្រមនាពេលបច្ចុប្បន្នរបស់អង្គការអ្នក ជួយរំលេចចំណុចខ្លាំងរបស់គ្រួសារ និងសហគមន៍ ដើម្បីពង្រឹងកិច្ចការពារ និងថែទាំកុមារតាមវិធីណាខ្លះ? តើមានឱកាសអ្វីខ្លះនៅក្នុងការងារ ឬអង្គការរបស់អ្នក ដើម្បីបង្កើនការប្រើប្រាស់គោលវិធីផ្អែកលើភាពខ្លាំងនៅក្នុងការងារសង្គមកិច្ច ហើយតើអ្នកគិតថា អភិក្រមនេះមានៈអត្ថប្រយោជន៍យ៉ាងណាខ្លះសម្រាប់កុមារ និងគ្រួសាររបស់កុមារ?
- តើការពង្រឹងសិទ្ធិអំណាចដល់គ្រួសារ អាចជះឥទ្ធិពលជាវិជ្ជមានយ៉ាងណាខ្លះ ចំពោះការគិតរបស់ពួកគេ ហើយតើការផ្លាស់  ប្តូរផ្នត់គំនិតទាំងនេះ ជួយលើកកម្ពស់លទ្ធផលនៃកិច្ចការពារកុមារ និងជួយបង្ការការបំបែកកុមារពីគ្រួសារដោយរបៀបណាខ្លះ?
- តើអ្នកធ្វើការជាមួយគ្រួសារដោយរបៀបណាខ្លះ ដើម្បីឆ្លើយតបហានិភ័យចំពោះកុមារ ដោយមិនបង្កឱ្យគ្រួសារមានអារម្មណ៍ថា ខ្លួនត្រូវបានគេវិនិច្ឆ័យ ឬដកសិទ្ធិអំណាចចេញពីខ្លួន? តើមានបញ្ហាប្រឈមអ្វីខ្លះចំពោះការរក្សាឱ្យមានតុល្យភាពត្រឹមត្រូវ ហើយតើមានអ្វីខ្លះដែលអាចកែសម្រួលបានដើម្បីតម្រង់ទិសបញ្ហាប្រឈមទាំងនេះ ឱ្យងាកទៅរកភាពប្រសើរឡើង? តើការកែសម្រួលទាំងនោះ នឹងបង្កឱ្យមានផលប៉ះពាល់យ៉ាងណាខ្លះ បើគិតទៅលើដំណើរការ ជំនាញ និងធនធាន?

ចំណុចពិភាក្សា៖

## ការកំណត់អត្តសញ្ញាណហានិភ័យ

នៅក្នុងវីដេអូនេះ លោក សោភ័ណ្ឌ លើកឡើងដោយបញ្ជាក់ថា ការកំណត់ហានិភ័យ ត្រូវរងឥទ្ធិពលពីចំណេះដឹងស្តីពីបរិបទរបស់សហគមន៍ និងសមត្ថភាពរបស់អ្នកសង្គមកិច្ចក្នុងការអភិវឌ្ឍទំនាក់ទំនងជាមួយគ្រួសារ និងបានទទួលការទុកចិត្តពីគ្រួសារ។ លោកបញ្ជាក់អំពីគ្រោះថ្នាក់នៃការទាញសេចក្តីសន្និដ្ឋានសើៗផ្អែកតែទៅលើហានិភ័យដែលស្តែងចេញ និង/ឬត្រូវបានកំណត់ឃើញក្នុងដំណើរការនៃការបញ្ជូនករណី។

## ក្នុងបរិបទរបស់អ្នក៖

? តើនរណាជាអ្នកទទួលខុសត្រូវក្នុងការកំណត់ហានិភ័យនៅក្នុងគ្រួសារ ហើយតើដំណើរការអ្វីដែលត្រូវបានយកមកប្រើប្រាស់? តើដំណើរការទាំងអស់នេះ ជួយដល់ការកំណត់រកហានិភ័យនៅកម្រិតសើៗ ឬហានិភ័យនៅកម្រិតបុព្វហេតុឫសគល់? សូមពិចារណាលើចំណុចខាងក្រោមនៅក្នុងការពិភាក្សារបស់អ្នក៖

- ការស្គាល់ បរិបទសហគមន៍ និងទំនៀមទម្លាប់
- ពេលវេលាដែលបានវិនិយោគក្នុងការកសាងទំនាក់ទំនង និងទំនុកចិត្ត
- កម្រិតនៃការចូលរួមរបស់គ្រួសារក្នុងការកំណត់ហានិភ័យ
- ប្រភេទគោលវិធី និងឧបករណ៍ដែលត្រូវបានប្រើប្រាស់ ដើម្បីជួយដល់ការកំណត់អត្តសញ្ញាណហានិភ័យ និងការវិភាគ
- លក្ខណសម្បត្តិនៃហានិភ័យដែលអ្នកកំពុងឆ្លើយតប (តើហានិភ័យទាំងនោះ គឺជារោគសញ្ញា ឬជាហានិភ័យបុព្វហេតុ?)

? សូមគិតអំពីករណីណាមួយដែលអ្នកដឹងច្បាស់ រួចពិចារណាថាតើគោលវិធីនេះ មានផលប៉ះពាល់អ្វីខ្លះមកលើគ្រួសារ? តើអ្នកមើលឃើញគ្រួសារមានភាពធន់ទ្រាំ និងសមត្ថភាពកាន់តែច្រើនឡើងដើម្បីទប់ទល់ជាមួយហានិភ័យនេះ ឬទេ?

? តើអង្គការរបស់អ្នកអាចកែលម្អគោលវិធីរបស់ខ្លួនយ៉ាងណាខ្លះនៅក្នុងការកំណត់ហានិភ័យ និងការវិភាគ? តើមានជំហានបន្ទាប់ និងត្រូវការធនធានអ្វីខ្លះ ដើម្បីអនុវត្តន៍?

## ការងារសង្គមកិច្ចតាមភូមិ និងការពង្រឹងគ្រួសារ

ដារី ដែលជាបុគ្គលិកសង្គមកិច្ចតាមភូមិមួយរូបរបស់អង្គការទំនុកចិត្តកុមារកម្ពុជា បានទទួលករណីបញ្ជូនពីអង្គការជាភាគី ទីបី សម្រាប់កុមារជាបងប្អូនបង្កើតបីនាក់ នៅក្នុងសហគមន៍គោលដៅរបស់នាង។ កុមារដែលមានអាយុចាប់ពី ៥ ដល់ ៩ ឆ្នាំទាំងនោះ ត្រូវបានរាយការណ៍ថាមានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ ទៅរៀនមិនទៀតទាត់ និងប្រឈមហានិភ័យដោយសារតែពួកគេរស់នៅក្នុងលំនៅដ្ឋានគ្មានសន្តិសុខ។

ដារី បានចុះទៅសួរសុខទុក្ខដល់គ្រួសារ នាងបានណែនាំខ្លួនប្រាប់គ្រួសារនោះថា នាងជាអ្នកសង្គមកិច្ចមួយរូបរបស់អង្គការទំនុកចិត្តកុមារកម្ពុជា មកពីភូមិក្បែរនេះ។ បន្ទាប់ពីកិច្ចសន្ទនាដំបូង គ្រួសារនោះដឹងថា ពួកគាត់ស្គាល់សាច់ញាតិមួយចំនួនរបស់ ដារី និងស្គាល់គ្រួសារផ្សេងទៀតនៅក្នុងភូមិ ដែល ដារី កំពុងជួយជ្រោមជ្រែង។ ចំណុចនេះ ធ្វើឱ្យពួកគេមានអារម្មណ៍ធូរស្បើយ ហើយពួកគេបានអញ្ជើញ ដារី ឱ្យអង្គុយញ៉ាំទឹកតែជាមួយពួកគាត់នៅក្នុងផ្ទះ។

ដារី អាចសង្កេតមើលផ្ទះនោះ និងមើលឃើញថា មានតែជញ្ជាំងពីរប៉ុណ្ណោះដែលត្រូវបានសាងសង់ឡើងដោយវត្ថុធាតុដើម មានសន្តិសុខគ្រប់គ្រាន់។ ចំណែកជញ្ជាំងពីរទៀត ត្រូវបានបិទបាំងដោយការ៉ុងចាស់ៗចងភ្ជាប់ជាមួយបង្គោលឫស្សី។ ដារី បានសាកសួរឪពុកម្តាយអំពីគ្រួសាររបស់គាត់ ហើយតាមរយៈកិច្ចសន្ទនានោះ ដារី បានដឹងថា ឪពុកម្តាយរបស់ស្ត្រីជាម្តាយកុមារនោះ និងបងស្រី និងគ្រួសាររបស់បងស្រីគាត់នៅផ្ទះជាប់របងគ្នាជាមួយផ្ទះរបស់កុមារ។ ដារី ជាអ្នករស់នៅក្នុងតំបន់នេះតាំងពីតូច ហើយនាងដឹងច្បាស់ថាលំនៅដ្ឋានបែបនេះ គឺជាលំនៅដ្ឋានជាទូទៅសម្រាប់គ្រួសារក្រីក្រ។ នាងក៏ដឹងដែរថា ឪពុកម្តាយគេងក្បែរកូនៗក្នុងផ្ទះមានបន្ទប់តែមួយ ហើយនៅក្នុងភូមិទាំងនេះ មិនដែលមានចោរនោះទេ ។ គ្រួសារក៏មានសន្តិសុខបន្ថែមទៀតដោយសារមានសាច់ញាតិរស់នៅជាប់របងគ្នាដែរ។ ដារី ទាញសេចក្តីសន្និដ្ឋានថា ទីកន្លែងនេះ មានកត្តាការពារគ្រប់គ្រាន់ដើម្បីគ្រប់គ្រងលើរាល់ហានិភ័យពាក់ព័ន្ធជាមួយលំនៅដ្ឋានគ្មានសន្តិសុខ ហើយទិដ្ឋភាពនេះពុំទាមទារឱ្យមានអន្តរាគមន៍ទេ។

ក្រោយពីបានចុះសួរសុខទុក្ខច្រើនដង គ្រួសារចាប់ផ្តើមបើកចំហអំពីបញ្ហាប្រឈមរបស់ខ្លួនមួយចំនួន និងបានពិភាក្សាជាមួយ ដារី អំពីអ្វីដែលពួកគាត់ចង់ធ្វើដើម្បីដោះស្រាយបញ្ហាទាំងនេះ។ បុព្វហេតុចម្បងនៃភាពតានតឹងក្នុងគ្រួសារ គឺបណ្តាលមកពីការងារមិនទៀងទាត់ដែលមានន័យថា ពេលខ្លះពួកគាត់ពុំមានចំណូលគ្រប់គ្រាន់ដើម្បីទិញអាហារ ឬចំណាយលើថ្លៃទៅសាលារៀនសម្រាប់ការអប់រំកូនៗរបស់ខ្លួននោះទេ។ ភាពតានតឹងផ្នែកហិរញ្ញវត្ថុក្នុងគ្រួសារ ក៏បង្កឱ្យមានភាពតានតឹងរវាងឪពុកម្តាយផងដែរ។

ម្តាយចង់ចាប់ផ្តើមលក់អីវាន់តិចតួចនៅមុខផ្ទះរបស់ខ្លួន ប៉ុន្តែគាត់ត្រូវការដើមទុនបន្តិចបន្តួចដើម្បីទិញទំនិញយកមកលក់។  ដារី បានជួយគ្រួសារឱ្យអភិវឌ្ឍផែនការដើម្បីបង្កើតជាអាជីវកម្មតូចមួយ ហើយស្របពេលជាមួយគ្នានោះ ក៏បានបញ្ជូនកុមារទៅវត្តនៅក្នុងភូមិ ព្រោះនៅវត្តនោះមានផ្តល់អាហារដោយឥតគិតថ្លៃដល់គ្រួសារជួបការលំបាក។ នាងក៏បានបញ្ជូនគ្រួសារទៅជួបសមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកស្ត្រី និងកុមារ ដើម្បីទទួលបានអាហារូបករណ៍ក្នុងទឹកប្រាក់តិចតួចតាមរយៈឃុំសម្រាប់ការអប់រំ ដើម្បីធានាឱ្យបានថា កុមារនៅតែបន្តទៅសាលារៀន។
អង្គការទឹកចិត្តកុមារកម្ពុជា បានផ្តល់ដើមទុនតិចតួចសម្រាប់ម្តាយឱ្យចាប់ផ្តើមអាជីវកម្មរបស់ខ្លួន ជាហេតុធ្វើឱ្យគាត់អាចជួយបំពេញបន្ថែមលើប្រាក់ចំណូលរបស់ឪពុក។

ដារី បន្តទៅសួរសុខទុក្ខគ្រួសារជាប្រចាំ ដើម្បីពិនិត្យតាមដានលើសុខុមាលភាពរបស់កុមារ លើកទឹកចិត្តឪពុកម្តាយ និងជួយពួកគាត់ឱ្យកំណត់គោលដៅ។ ថ្វីបើបញ្ហានៅតែបន្តកើតមានក្តី ប៉ុន្តែយូរៗ ទៅ សមត្ថភាពរបស់គ្រួសារក្នុងការទប់ទល់ និងជម្នះលើបញ្ហាទាំងអស់នេះតាមរយៈមធ្យោបាយរបស់ខ្លួនផ្ទាល់មានភាពកើនឡើង ជាហេតុធ្វើឱ្យអាចកាត់បន្ថយហានិភ័យពាក់ព័ន្ធនានាចំពោះកូនៗរបស់ពួកគេ។